01043189 F14

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Dec-2014, 14:01
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា៖**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

លីវ សុវណ្ណា

Doreen CHEN

Joshua ROSENSWEIG

Xiaoyang NIE

**ចម្លងជូន៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

អនុលោមតាមវិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុងរបស់ អវតក សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") តទៅនេះសូមដាក់សំណើបន្ទាន់ សុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១:

១. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ("បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")[1]។

២. នៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ សហមេធាវីការពារក្តីរបស់ ខៀវ សំផន បានស្នើសុំតុលាការកំពូលនូវពេលវេលាបន្ថែមដើម្បីដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[2]។

៣. មេធាវីការពារក្តីមានបំណងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងស្នើសុំពេលវេលាដូចគ្នាដើម្បីឆ្លើយតប។ មេធាវីការពារក្តីសូមដាក់នូវហេតុផលដែលបានលើកឡើងដោយសហមេធាវីការពារក្តីរបស់លោក ខៀវ សំផន ដើម្បីសុំពន្យារពេល[3]។

៤. សម្រាប់ហេតុផលដូចនេះ មេធាវីការពារក្តីសូមស្នើដល់តុលាការកំពូលដូចតទៅ:

   a. ដាក់ពេលវេលាកំណត់រយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ សម្រាប់ដាក់ការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និង

   b. ចេញសេចក្តីសម្រេចជាបន្ទាន់លើសំណើនេះ ដោយសារតែពេលវេលាកំណត់សម្រាប់ដាក់ការឆ្លើយតបរបស់មេធាវីការពារក្តីទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជិតចូលមកដល់។

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ Victor KOPPE

---

[1] ឯកសារ F11 "បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១" ពី ERN 01040229 ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[2] ឯកសារ F12 "សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា" ពី ERN 01040344 ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ("សំណើសុំពន្យារពេលរបស់ ខៀវ សំផន")។

[3] ឯកសារ F12 សំណើសុំពន្យារពេលរបស់ ខៀវ សំផន ពីកថាខណ្ឌទី៣ ដល់ ៦។